# ប្រាសាទយាយព័ន្ធ តួប៉ម S17-6

ក្រុមប្រាសាទយាយព័ន្ធ ឬក្រុមខាងត្បូង គឺជាក្រុមប្រាសាទដ៏សំខាន់មួយនៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុក។ នៅក្នុងក្រុមនេះមានប្រាសាទសរុបចំនួន ៣៥ ហើយតួប៉មដែលសំខាន់ជាងគេ គឺតួប៉មនៅកណ្ដាល ចុះបញ្ជី ឧទ្ទិសដល់ព្រះឥស្សរដែលមានព្រះនាមថា *ស្រីប្រហសិតេស្វរៈ* (Çrīprahasiteçvaraḥ) ឬមានន័យជាភាសាខ្មែរថា "*ព្រះសិរីញញឹម*។ ក្រៅពីតួប៉មកណ្ដាល ក្នុងក្រុមប្រាសាទយាយព័ន្ធ មានតួប៉មប្រាសាទប្រាំបីជ្រុងចំនួន ៦ ទៀត ដែលជាស្ថាបត្យកម្មពិសេសល្អឯកមួយប្រចាំតំបន់សំបូរព្រៃគុក។ អ្វីដែលគួរកត់សម្គាល់ផ្សេងទៀតនោះ គឺក្រុមប្រាសាទយាយព័ន្ធ គឺជាក្រុមប្រាសាទមួយនៅតំបន់ប្រាសាទសំបូរព្រៃគុក ដែលសម្បូណ៌ដោយតួប៉មប្រាសាទសាងអំពីថ្មបាយក្រៀម។ ប្រាសាទថ្មបាយក្រៀមទាំងនោះមានចំនួន ៦ សង់នៅបរិវេណកំពែងខាងក្រៅ មានរាងបួនជ្រុងស្មើ បែរមុខទៅកើត និងសុទ្ធសឹងមានកំពែងព័ទ្ធជុំវិញគ្រប់តួប៉មទាំងប្រាំមួយ ហើយបើមើលទៅដូចជាតួប៉មរណបមួយឱ្យសំណង់សំខាន់ដែលនៅបរិវេណកំពែងខាងក្នុង។ ប្រាសាទថ្មបាយក្រៀមទាំងប្រាំមួយនេះ ចុះបញ្ជី S17-4, S17-5, S17-6, S17-7, S17-8, S17-9 (សូមមើលប្លង់លេខ១)។ សំណង់ទាំងប្រាំមួយនេះ ភាគច្រើនបានបាក់បែកស្ទើរទាំងស្រុងទៅហើយ (រូបលេខ១-២) លើកលែងតែតួប៉មចំនួនពីរដែលនៅសល់រូបរាងគ្រាន់បើ ពោល គឺតួប៉មដែលចុះបញ្ជីលេខ S17-5 និង S17-6។ នៅទីនេះ យើងសូមលើកយកតែតួប៉ម S17-6 មកបរិយាយប៉ុណ្ណោះ ដ្បិតវាជាតួប៉មដែលសំខាន់ជាងគេក្នុងចំណោមតួប៉មប្រាសាទថ្មបាយក្រៀមទាំង ៦ នៅក្រុមប្រាសាទយាយព័ន្ធ ដែលគេអាចចាត់ទុកថា ជាសំណង់ប្រាសាទថ្មបាយក្រៀមដែលសង់ឡើងដំបូងៗនៅក្នុងសិល្បៈខ្មែរ។ តើប្រាសាទយាយព័ន្ធ តួប៉ម S17-6 មានលក្ខណៈបែបណាខ្លះ?

តួប៉ម S17-6 មានទីតាំងស្ថិតនៅខាងជើងតួប៉មកណ្ដាលនៃក្រុមប្រាសាទយាយព័ន្ធ និងស្ថិតនៅក្នុងបរិវេណកំពែងខាងក្រៅ។ តួប៉មនេះ សាងឡើងអំពីថ្មបាយក្រៀម មានរាងបួនជ្រុងស្មើ ប្រវែង ៤,៥ម៉ែត្រ គុណ ៤,៥ម៉ែត្រ មានកំពែងព័ទ្ធជុំវិញធ្វើអំពីថ្មបាយក្រៀមដូចគ្នា បែរមុខទៅទិសខាងកើត (រូបលេខ៣-៤)។ សព្វថ្ងៃ តួប៉មនេះនៅសល់រូបរាងដើមត្រឹមពាក់កណ្ដាល ដោយអាចនៅឈរត្រឹមកម្ពស់ ១,៥០ម៉ែត្រ ព្រមទាំងមានការលម្អជាក្បាច់ផ្សេងៗនៅឃឿនខាងក្រោម។ នៅប្រាសាទនេះ គេធ្លាប់រកឃើញផ្ដែរទ្វារចំនួនមួយផ្ទាំង ឆ្លាក់បង្ហាញអំពីរូបសត្វមករនៅសងខាងបែរមុខចូលក្នុង និងមានលម្អក្បាច់មេដាយ៉ុងចំនួនបីឆ្លាក់ជារូបទេពផ្សេងៗដូចផ្ដែរជាច្រើនទៀតនៅតំបន់សំបូរព្រៃគុកដែរ (រូបលេខ៥)។ អ្វីដែលធ្វើឱ្យអ្នកស្រាវជ្រាវកត់សម្គាល់ខ្លាំងអំពីតួប៉ម S17-6 គឺតួប៉មនេះធ្លាប់រកឃើញសិលាចារឹកមួយដែលចារនៅលើមេទ្វារប្រាសាទ ចុះបញ្ជីលេខ K.៦០៤

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ចារនៅលើមេទ្វារមានចំនួន ៣០ បន្ទាត់ ស្មើនឹង ៣០ ស្លោក ចារឹកជាភាសាសំស្ក្រឹត ហើយសព្វថ្ងៃរក្សាទុកនៅសារមន្ទីរខេត្តកំពង់ធំ (រូបលេខ៦-៧)។ សិលាចារឹកនេះរកឃើញដំបូងដោយលោក Victor Goloubew ក្នុងឆ្នាំ១៩២៧ និងបានបោះពុម្ពផ្សាយបន្ទាប់ទៀតដោយលោក Louis Finot ។ ក្រោយមកទៀត នៅឆ្នាំ១៩៥២ លោក George Coédès បានប្រែដោយសង្ខេបឡើងវិញម្តងទៀត។[១] លោក George Coédès បានបញ្ជាក់ថា សិលាចារឹកនេះ រៀបរាប់អំពីមន្ត្រីម្នាក់ដែលមានវិជ្ជាជ្រៅជ្រះខាងផ្នែកព្រះពុទ្ធសាសនាឈ្មោះ "វិទ្យាវិសេស" ហើយលោកក៏គិតទៀតថា សិលាចារឹកនេះជាសិលាចារឹកនិយាយរឿងពុទ្ធសាសនាចំណាស់ជាងគេនៅកម្ពុជា។ ក្រោយមក នៅឆ្នាំ ២០១៨ លោក កំ វណ្ណាវ៉ា ក៏ធ្លាប់ប្រែសិលាចារឹកនេះទាំងស្រុងឡើងវិញម្តងទៀត។[២] ក្នុងឆ្នាំ២០១៩ លោក Dominic Goodall ក៏ធ្លាប់លើកយកសិលាចារឹកនេះមកសិក្សាម្តងទៀតក្នុងអត្ថបទមួយដែលចុះផ្សាយក្នុងឧទ័យ លេខ ១៤។[៣] សិលាចារឹកនេះ ផ្តល់កាលបរិច្ឆេទមហាសករាជឆ្នាំ៥៤៩ ត្រូវនឹង គ.ស.៦២៧ ដែលត្រូវរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ (គ.ស.៦១៦ ដល់ ៦៣៧)។

សិលាចារឹកនេះចាប់ឡើងដោយការគោរពអាទិទេព ទំនងជាព្រះសិវលិង្គ ដែលមានព្រះនាមថា "**ស្រីកទម្វេស្វរ**"។ គាថាបន្តរៀបរាប់ពោលសរសើរអំពីព្រះបាទឦសានវរ្ម័នទី១ ដែលទ្រង់មានអនុភាពខ្លាំងពូកែប្រៀបដូចព្រះវិស្ណុគ្រប់គ្រងលើសមុទ្រទាំងបួន អស្ចារ្យលើសព្រះឥន្ទ្រ ជាក្សត្រមានប្រាជ្ញាខ្ពង់ខ្ពស់។ ចាប់ពីគាថាទី៩ រៀបរាប់អំពីមន្ត្រីម្នាក់ដែលមានចំណេះដឹងជ្រៅជ្រះឈ្មោះថា "វិទ្យាវិសេស" ដែលជាអភិបាលក្រុងតមន្ទបុរ[៤] (តមន្ទបុរស្វាមិ)។ ដោយមានភក្តីភាពចំពោះព្រះឦសាន អភិបាលក្រុងនេះបានសង់សិវលិង្គមួយតម្កល់នៅប្រាសាទ ហើយយកដង្វាយមកពីស្រុកមួយឈ្មោះ "សាកតីថ៌" មានខ្ញុំបម្រើ គោ ក្របី ស្រែ និងបានប្រគល់ការងារគ្រប់គ្រងព្រះដង្វាយនេះដល់ព្រាហ្មណ៍ម្នាក់ឈ្មោះថា "បាសុបតៈ" ដែលបានតែងតាំងដោយព្រះរាជា។ នៅគាថាទី១៤ រៀបរាប់ថា នៅមហាសករាជឆ្នាំ៥៤៩ ត្រូវនឹងគ្រឹស្តសករាជឆ្នាំ៦២៧ អភិបាលក្រុងនេះ រួមជាមួយភោជនធំៗ (មន្ត្រីសំខាន់ៗ) កានកសាងរូបព្រះវិស្ណុមួយ។

នៅក្នុងការសិក្សារបស់លោក Dominic Goodall បានបញ្ជាក់ថា ក្រុងតមន្ទបុរ ដែលគ្រប់គ្រងដោយស្តេចត្រាញ់ម្នាក់ឈ្មោះ "វិទ្យាវិសេស" ទំនងស្ថិតនៅតំបន់ដីសណ្តទន្លេមេគង្គក្នុងដីវៀតណាម

---

[១] Coédès 1952:17-18.

[២] កំ វណ្ណាវ៉ា ២០១៨: ១៩។

[៣] Goodall 2019: 43-51.

[៤] Goodall 2019: 43-51.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

បច្ចុប្បន្ន ដ្បិត នៅទីនោះគេធ្លាប់រកឃើញសិលាចារឹកមួយទៀតដែលបញ្ជាក់អំពីឈ្មោះតំបន់តមន្ទបុរ ពោល គឺសិលាចារឹកចុះបញ្ជីលេខ K.9។[៥] ចំណុចនេះសបញ្ជាក់ឱ្យឃើញថា ទោះបីសង្គមខ្មែរនៅសម័យចេនឡាមិនរួបរួមក្រោមអំណាចតែមួយយ៉ាងណាក្តី ក៏នៅមានស្តេចត្រាញ់ជាច្រើននៅតំបន់ឆ្ងាយៗ នៅតែគោរពអំណាចរបស់ព្រះបាទឦសានវរ្ម័នទី១ ដែលសោយរាជ្យនៅក្រុងឦសានបុរ (សំបូរព្រៃគុក) ដែរ។ ជាក់ស្តែងសិលាចារឹកដែលប្រាសាទនេះបង្ហាញស្រាប់ ព្រមទាំងមានសិលាចារឹកផ្សេងៗជាច្រើនទៀតផង ឧទាហរណ៍ សិលាចារឹកប្រាសាទស្រីគ្រប់ល័ក្ខណ K.151 មានស្តេចត្រាញ់ម្នាក់ឈ្មោះ "នរសិង្ហគុប្ត" ដែលគ្រប់គ្រងនៅតំបន់ឥន្ទ្របុរ[៦] ។ល។

**អត្ថបទដើមជាអក្សរខ្មែរទំនើប**

**ស្លោកទី ១.**

(១). ត្រីកទម្វេគ្វរះ បាយាទិ អយំ អក្សីណសម្បទះ

(២). យុធ្មាន អគក្យនិទ្វេគ ប្រភាវាតិគយោទយះ។

**ស្លោកទី ២.**

(៣). វិក្រមាវជិតាម្ភោធិ បរិខាវនិមណ្ឌលះ

(៤). ត្រីគានវម្មៃត្យ អភវទ៑ រាជា វិឆ្លុរិ ឥវាបរះ។

**ស្លោកទី ៣.**

(៥). ប្រយុក្តនយមេត្រេណ កទាចិទ៑ អវនីភុជាំ

(៦). បក្សច្ចិទាបកត៌្វណាមិ ពជ្រី យេន វិគេមិតះ។

**ស្លោកទី ៤.**

(៧). យោ និរាក្ឫតនិគ្រេម កលិទុល្ល៌លិតិទយះ

(៨). វណ៌្ណមុច្ច៌ារិ អភូទ៑ ឯកោ យុគាទិប្ឫថវីភូជាំ។

**ស្លោកទី ៥.**

(៩). សំខ្យាតីតតយា យស្យ ក្រតូនាំ អមរាធិបះ

(១០). គតក្រតុក្ឫតនិ នាម មន្យេ ន ពហុ មន្យតេ។

**ស្លោកទី ៦.**

(១១). និរាជារមិ ឥទមិ មាភូទ៑ ទគ្វេ កុសុមជន្ទនិ

---

[៥] Coédès 1953:35, Goodall 2019: 74.

[៦] Coédès 1943: 5.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

(១២). ឥតិ វិគ្វម្ភជា នូនមិ      វបុរ៑ យត្រ និវេគិតមិ។

**ស្លោកទី ៧.**

(១៣). តេន ភូមិកុជា វ្យាប្ត      ទិគា មណ្ឌលកីត្តិនា

(១៤). ភ្ឫត្យោ យោ ធិភ្ឫតសិ      សវ៌្វម្ ឥតិកត៌្យវស្តុមុ។

**ស្លោកទី ៨.**

(១៥). គព្ទវៃគេមិកាន្យាយ      សមីក្ឞសុគតាធ្វនាមិ

(១៦). ធុរិយោ លិខិតោ      នេកគាស្ត្រប្រហតវុទ្ធិកិះ។

**ស្លោកទី ៩.**

(១៧). កវិរ៑ វ្វាទី សុហ្ឫទ្វគ្គ៌      អាត្មប្រាណាទិ អមន្យតា

(១៨). វិទ្យាវិគេមនាមា យ      អាចាយ៌្យោ លោកវេទិតា។

**ស្លោកទី ១០.**

(១៩). ឥច្ឆតា ភក្តិមិ ឰគានេ      ស្ដិរាញ្ញា ជន្មនី ជន្មនី

(២០). តេនេហ ស្ដាបិតំ ឥទំ      លិង្គំ គុទ្ធាភិសន្ធិនា។

**ស្លោកទី ១១.**

(២១). គាកតីថមិ ឥតិ គ្រាមោ      ទត្តិរ៑ ឰគាយ យជ្វនះ

(២២). ភ្ឫត្យគោមហិធារាម      ក្ឞេត្រប្រវ្ឫត្តិបូរិតះ។

**ស្លោកទី ១២.**

(២៣). ទ្វិជះ បាគុបតោ      រាជ្ញាធិភ្ឫតោ ទេវតាច៌្ចនេ

(២៤). ឥទនិ ទេវកុលំ ភោក្តុំ      អហ៌ត្យ អាភូតសំប្លវមិ។

**ស្លោកទី ១៣.**

(២៥). តេន មា វគ្យកត៌្តវ្យំ      អស្យ យត្នេន បាលនមិ

(២៦). ស្វបុណ្យស្សេវ សទ្វគ្គ៌      ភ្ឫតំ អាគិបំ ឥច្ឆតា។

**ស្លោកទី ១៤.**

(២៧). ទ្វារពណ្ណ៌វេមុគាកាព្ទេ      ទ្វារិង្គេ បុម្យយោគិនិ

(២៨). ឥមស្យ ទិវសេ សិង្ហលគ្នេ      ចាយំ ស្ដិតោ ហរះ។

**ស្លោកទី ១៥.**

(២៩). ភ្ឫតេបុណ្យាធិការេ ស្មិន្ន      អថ យជ្វា ស ភូកុជា

អត្ថបទដោយៈ ម៉ង់ វ៉ាលី

KHMER CIVILIZATION

(៣០). តមន្ទរបុរស្វាមិ ភោជកប្រវរៈ ក្វតះ។

## សេចក្តីប្រែសម្រួលជាភាសាខ្មែរទំនើប[៧]

**ស្លោកទី ១.**

សូមឱ្យព្រះស្រីកទម្ពេស្វរ ជាប្រភពនៃសេចក្តីរុងរឿងគ្មានដែនកំណត់តាមការពារនិងផ្តល់នូវសុខសុភមង្គល ដល់អ្នកជាជរាបតទៅ។

**ស្លោកទី ២.**

មានព្រះរាជាមួយព្រះអង្គមានព្រះបរមនាមថា ស្រីសានវម៌្ម ដែលព្រះអង្គ ប្រៀបប្រដូចបានទៅនិងតួអង្គព្រះវិស្ណុមួយអង្គ ព្រះអង្គទ្រង់បានឈ្នះដោយវីរភាពដ៏អង់អាចក្លាហាន នូវផែនដីទាំងមូល និងសមុទ្រទាំង៤។

**ស្លោកទី ៣.**

ដោយបានយកឈ្នះលើកងទ័ព នៃក្សត្រដែលជាសត្រូវទាំងឡាយតាមរយៈ ការប្រើឧបាយកលតែមួយគត់ ព្រះអង្គទ្រង់អស្ចារ្យលើសទេព ដែលមានហត្ថាកាន់គ្រាប់រន្ទះ(ព្រះឥន្ទ)ទៅទៀត។

**ស្លោកទី ៤.**

ព្រះអង្គបានរាំងនូវការរីករាលដាលនូវអំពើអាក្រក់ (អំពើរបាបរបស់របស់ពួកកាលី) ទ្រង់បាន

ធ្វើឡើងដោយព្រះអង្គផ្ទាល់នូវសារតារ កិត្តិនាមនៃក្សត្រ ក្នុងយុគដំបូងៗ។

**ស្លោកទី ៥.**

មានភាពខ្ពង់ខ្ពស់តាមរយៈការធ្វើពលីកម្មរបស់ទ្រង់ ខ្ញុំគិតថាស្តេចនៃទេពនេះមិនជាប់ពាក់ព័ន្ធច្រើននឹងតម្លៃនៃព្រះកិត្តិនាម ដែលគេផ្តល់តម្លៃឲ្យទ្រង់នូវពលីកម្មទាំង១០០របស់ទ្រង់។

**ស្លោកទី ៦.**

ភាពប្រាកដ មានចំពោះទ្រង់ ដោយព្រះព្រហ្មបានបង្កើតរាង្គកាយមួយ ដើម្បីឱ្យសេចក្តីស្នេហា ដែលបានរលាយសាបសូន្យ ដោយគ្មានការគាំទ្រ។

**ស្លោកទី ៧.**

---

[៧] ប្រែសម្រួលដោយ កំ វណ្ណារ៉ា ២០១៨: ១៩។

ព្រះរាជាអង្គនេះហើយ ដែលទ្រង់បរិបូណ៌ដោយព្រះកិត្តិនាម ធ្វើឲ្យដែនដីរបស់ទ្រង់ រីកសន្ធឹកទៅទិសទាំង៤ ហើយទ្រង់បានចាត់អ្នកបម្រើទ្រង់ម្នាក់ ឲ្យប្រតិបត្តិតាមបទបញ្ជារបស់ទ្រង់។

**ស្លោកទី ៨.**

ព្រះរាជាអង្គនេះ ព្រះអង្គត្រូវបានគេប្រកាសថា ជាក្សត្រមានប្រាជ្ញា មានចំណេះវិជ្ជាច្រើនប្រៀបប្រដូចនឹងក្បួនវេយ្យាករណ៍ដូចជា វៃសេសិក:, ន្យាស:,សមីក្ស និងក្នុងព្រះពុទ្ធសាសនា។

**ស្លោកទី ៩.**

កវីពូកែខាងសំនួនវោហារ ដែលស្គាល់ពិភពលោក ទាំងមូល គ្រូទាំងនេះត្រូវបានគេប្រសិទ្ធិនាមថា វិទ្យាវិសេស គួរជាទីគោរពរាប់អានរបស់មិត្តភក្តិទាំងឡាយ។

**ស្លោកទី ១០.**

ដោយបានប៉ងប្រាថ្នា ដោយភក្តី ចំពោះព្រះឦសានស្ថិតស្ថេរទៅជាដរាប ពីសម័យកាលមួយ ទៅសម័យកាលមួយ ទ្រង់បានស្ថាបនាព្រះសិវលិង្គនេះ ដើម្បីឧទ្ទិសព្រះកាយដ៏បរិសុទ្ធរបស់ទ្រង់។

**ស្លោកទី ១១.**

មានគ្រាម(ស្រុក)មួយឈ្មោះថា សាកតីថ៌ ដែលសម្បូរដោយខ្ញុំបម្រើ គោ ក្របី អារាម ស្រែជាតង្វាយចំពោះព្រះឦស:។

**ស្លោកទី ១២.**

ព្រាហ្មណ៍ បាសុបត:ម្នាក់បានទទួលការតែងតាំងពីព្រះមហាក្សត្រ ដើម្បីបម្រើព្រះ ត្រូវមើលខុសត្រូវ រាល់ចំណូលរបស់ទេវាល័យរហូតអស់ផែនដី។

**ស្លោកទី ១៣.**

គាត់មិនត្រូវធ្វើអ្វីៗតាមអំណាចចិត្តទេ ក្រៅតែអំពីការពារទ្រព្យសម្បត្តិនេះ ឱ្យដូចជាសម្បត្តិរបស់គាត់ ប្រសិនបើគាត់ចង់បានការប្រទានពរតាមការសេចក្តីប្រាថ្នា។

**ស្លោកទី ១៤.**

នៅក្នុងឆ្នាំស.ក.កំណត់ដោយ ព្រួញ=៥ សមុទ្រ=៤ ទ្វារ=៩ ថ្ងៃទី២២ ខែឦស:(អស្វិន)ក្នុងរាសីខែបុស្ស សិង្ហរាសី(សិង្ហស្ថិតនៅជើងមេឃ) ព្រះបដិមាហរិត្រូវបានសាងឡើង។

**ស្លោកទី ១៥.**

ការស្ថាបនានេះបានចប់ស្រេច ស្ថាបនាដោយអភិបាលក្រុងបមន្ទរបុរ: និងភោជកធំៗ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ជារួមមក បើពិនិត្យមើលតាមរចនាសម្ព័ន្ធរបស់ប្រាសាទ សិល្បៈ និងអត្ថន័យរបស់សិលាចារឹក យើងអាចទាញសេចក្តីសន្និដ្ឋានបានថា ប្រាសាទយាយព័ន្ធ តួប៉ម S17-6 និងប្រាសាទថ្មបាយក្រៀមចំនួន ៥ ទៀត ទំនងសាងឡើងនៅក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ ឧទ្ទិសដល់ព្រហ្មញ្ញសាសនា និកាយព្រះឥសូរ និងជាសំណង់រណបនៃប្រាសាទសំខាន់នៅតួប៉មកណ្តាល ហើយអាចជាសំណង់ឧបត្ថម្ភគាំទ្រដោយលោក វិទ្យាវិសេស ជាអភិបាលក្រុងតមន្ទបុរ។ លក្ខណៈពិសេសគួរកត់សម្គាល់ខ្លាំងនោះគឺ ប្រាសាទថ្មបាយក្រៀមនេះ ទំនងសាងឡើងសម័យកាលដំបូងនៅក្នុងសិល្បៈខ្មែរ។

## ឯកសារយោង

**កំ វណ្ណារ៉ា**

២០១៨ “*ប្រជុំសិលាចារឹកខេត្តកំពង់ធំ*, ភ្នំពេញ

**Cœdès Georges**

1943, “Quelque précisions sur la fin du Fou-Nan” *BEFEO*, Tome 43, Paris
1952, “*Inscription du Cambodge*” Tome 4, Hanoi puis Paris
1953, “*Inscription du Cambodge*” Tome 5, Hanoi puis Paris

**Dominique Goodall**

2019, Nobles, bureaucrats or strongmen? On the “Vassal Kings” or “Hereditary Governors” of pre-Angkorian city-states : Two Sanskrit inscriptions of Vidyavisesa, seventh-century governor of Tamandarapura (K.1235 and K.604), and an inscription of Sivadatta (K.1150), previously considered a son of Isanavarman I, *UDAYA*, No.19, Phnom Penh

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៖ ប្រាសាទយាយព័ន្ធ តួប៉ម S17-4 សាង់ពីថ្មបាយក្រៀម (មើលពីខាងកើត)



រូបលេខ២៖ ប្រាសាទយាយព័ន្ធ តួប៉ម S17-5 សាង់ពីថ្មបាយក្រៀម (មើលពីខាងកើត)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ប្រាសាទយាយព័ន្ធ តួប៉ម S17-6 សាង់ពីថ្មបាយក្រៀម (មើលពីខាង់កើត)



រូបលេខ៤៖ ប្រាសាទយាយព័ន្ធ តួប៉ម S17-6 សាង់ពីថ្មបាយក្រៀម (មើលពីទិសពាយព្យ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៥៖ ផ្តែរទ្វារ ប្រាសាទយាយព័ន្ធ តួប៉ម S17-6



រូបលេខ៦៖ សិលាចារឹក K.៦០៤ រកឃើញនៅប្រាសាទយាយព័ន្ធ តួប៉ម S17-6

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៧៖ ក្រដាសផ្តិតសិលាចារឹក K.៦០៤ (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី




ប្លង់លេខ១៖ ប្លង់លម្អិតក្រុមប្រាសាទយាយព័ន្ធ (ប្រភព៖ SCP)

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី